**បត្យាប័ន (Extradition)**

**១.** ក្នុងយុគសម័យ ដែលការធ្វើដំណើរមានភាពងាយស្រួល ឧក្រិដ្ឋជន អាចគេចពីសំណាញ់ច្បាប់ និងរត់ទៅជ្រកកោនក្នុងប្រទេសមួយ។ បត្យាប័ន ជាយន្តការ តាមរយៈនេះ រដ្ឋធ្វើសំណើ អាចស្នើសុំរដ្ឋទទួលសំណើ បញ្ជូនឧក្រិដ្ឋជនមកទទួលការកាត់ទោស ឬ ទទួលអនុវត្តទោស។ ក្នុងន័យនេះ បត្យាប័នខុសពី ការបណ្តេញចេញ (deportation) ដែលសំដៅលើការដេញជនបរទេស ដែលអស់ទិដ្ឋាការសម្រាប់ស្នាក់នៅ។ វាក៏ខុសអំពី ពីការបញ្ជូន (surrender) ដោយរដ្ឋទៅកាន់តុលាការព្រហ្មទណ្ឌអន្តរជាតិ នូវជនល្មើស ដោយរដ្ឋជាសមាជិកតុលាការ ដែលមានកាតព្វកិច្ចបញ្ជូន។ ដោយសារបត្យាប័នឆ្លងកាត់នីតិវិធីស្មុគ្រស្មាញ រដ្ឋខ្លះ បានប្រើនីតិវិធីក្រៅផ្លូវការដើម្បីទទួលបានឧក្រិដ្ឋជន (disguised extradition)។

**២.** កាតព្វកិច្ច ធ្វើបត្យាប័ន មានក្នុងទម្រង់ច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឬសន្ធិសញ្ញា ពហុភាគី ឬទ្វេភាគី ដូចជាសន្ធិសញ្ញារវាងកម្ពុជា និងរដ្ឋបរទេសមួយចំនួនhttp://www.measboralaws.com/detail/856 ។ ប្រទេសខ្លះព្រមធ្វើបត្យាប័ន ដោយមិនចាំបាច់មានកិច្ចព្រមព្រៀងទេ តាមគោលការណ៍បដិការ (reciprocity)។ នេះប្រកាន់យកភាគច្រើនដោយរដ្ឋនៃប្រព័ន្ធស៊ីវិលឡូ។ រដ្ឋក្រុមនេះ ជាទូទៅមិនធ្វើបត្យាប័នជនជាតិខ្លួនទេ ដែលតម្រូវឲ្យមានយុត្តាធិការទូលាយ សម្រាប់កាត់ទោសប្រជាពលរដ្ឋខ្លួន ដែលប្រព្រឹត្តបទល្មើសនៅក្រៅប្រទេស តាមគោលការណ៍ Active Nationality Principle។ ក្នុងដំណើរការបត្យាប័ន រដ្ឋនៃប្រព័ន្ធស៊ីវិលឡូ ទាមទារតែឯកសារគាំទ្រមួយចំនួនខុសគ្នានឹងប្រទេសនៃប្រព័ន្ធកុំមុនឡូ ដែលទាមទារនូវកម្រិតភស្តុតាងបង្ហាញថា បុគ្គលដែលគេចង់បាន បានប្រព្រឹត្តិបទល្មើស (reasonable basis to believe that the person committed the offence)។ បន្ថែមពីលើនេះ ប្រទេសកុំមុនឡូ ប្រកាន់យកយុត្តាធិការចង្អៀត មានសមត្ថកិច្ចកាត់ទោសតែបទល្មើសកើតក្នុងដែនដីខ្លួន។ ព្រោះហើយ ការធ្វើបត្យាប័នទៅរួច ជាទូទៅលុះត្រាមានកិច្ចព្រមព្រៀង។ ទោះបីជាយ៉ាងនេះក្តី កាតព្វកិច្ចបត្យាប័ន ទោះបីក្នុងសន្ធិសញ្ញាពហុ ឬទ្វេភាគី មិនមានភាពដាច់ខាតទេ។ អនុសញ្ញា ស្តីពីការប្រឆាំងនឹងអំពើទារុណកម្ម មាត្រា ៧ ចែងថា រដ្ឋបើមិនធ្វើបត្យាប័ន ត្រូវកាត់ទោសជនល្មើសដោយតុលាការខ្លួនឯង (*aut dedere aut judicare*)។

**៣.** ការធ្វើបត្យាប័ន ទាមទារនូវការគោរពគោលការណ៍ចម្បងមួយចំនួន ដូចជា ការតម្រូវថា បទល្មើសទោះមានឈ្មោះខុសគ្នាក្តី ត្រូវតែជាបទល្មើសចែងក្នុងច្បាប់របស់ប្រទេសទាំងពីរ (dual criminality) ដែលមានទោសយ៉ាងតិច ១ឆ្នាំ ឬ ទោសដែលត្រូវបានអនុវត្តក្នុងពន្ធនាគារនៅសល់៦ខែ (វាប្រែប្រួលតាមការកំណត់ច្បាប់ ឬសន្ធិសញ្ញានីមួយៗតម្រូវ)។ ទោះបីជាយ៉ាងនេះក្តី បទល្មើសមួយចំនួន មិនត្រូវបានចាត់ថាជាបទល្មើសអាចបត្យាប័នបានទេ

(extraditable offences) ដែលពីមុន បទល្មើសទាំងនេះមានច្រើន តែមកដល់ពេលនេះ នៅសល់ចំនួនតិចតួច ដូចជាបទ ល្មើសយោធា (military offence) ឬនយោបាយ (political offence)។ មិនមាននិយមន័យនៃបទល្មើសនយោបាយជាក់លាក់ទេ។ វាមានត្រឹមតែសញ្ញាណ ឧទាហរណ៍ ការសម្លាប់ប្រមុខរដ្ឋ មិនមែនជាបទល្មើសនយោបាយទេ។ ប្រទេសមួយចំនួន បានអភិវឌ្ឍនូវលក្ខណវិនិច្ឆ័យ សម្រាប់កំណត់ថាអ្វីជាបទល្មើសនយោបាយ ដោយផ្តោតសំខាន់ទៅលើគោលបំណងនៃសកម្មភាព គឺការផ្លាស់ប្តូររបបដឹកនាំនយោបាយ៖ ១. ជាសកម្មភាពនៃការរំខានផ្នែកនយោបាយ (political disturbance) ក៏ប៉ុន្តែមិនត្រូវនៅឆ្ងាយពីគោលដៅចុងក្រោយទេ (not too remote) (ប្រទេសអង់គ្លេស)។ ២. ស្រដៀងនឹងអង់គ្លេស តែបន្ថែមនូវគោលការណ៍សមាមាត្រ ដែលមានន័យថា ផលវិបាកនៃសកម្មភាព ត្រូវសមាមាត្រនឹងអ្វីចង់បាន។ ក្នុងន័យនេះ ការសម្លាប់មនុស្សដើម្បីសម្រេចបំណងនយោបាយ មិនទទួលយកបានទេ (ប្រទេសស្វីស)។ ៣. ទង្វើបង្កនូវការខូចខាតមិនរើសមុខ (indiscriminate attack)។ ដូចនេះ អំពើភេរវកម្មចូលក្នុងប្រភេទនេះ និងមិនត្រូវចាត់ជាបទល្មើសនយោបាយទេ (ប្រទេសអៀរឡង់) និងទី៤. សហរដ្ឋអាមេរិក ទាមទារថាសកម្មភាពជាផ្នែកនៃហិង្សានយោបាយ ហួសពីការរំខាន (disturbance)។ ក្នុងន័យនេះ បទល្មើសឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អាចជាបទល្មើសនយោបាយ។

**៤.** ដូចបានបញ្ជាក់ខាងលើ កាតព្វកិច្ចធ្វើបត្យាប័នមិនដាច់ខាតទេ។ វាមានកម្រិត ដែលនាំឲ្យមានការបដិសេធបាន។ មូលដ្ឋានបដិសេធមានពីរ គឺដាច់ខាត (mandatary grounds) និងមិនដាច់ខាត (optional grounds) http://www.measboralaws.com/detail/1043 ។ ទី១ រាប់បញ្ចូលនូវការហួសចិរវេលានៃការចោទប្រកាន់ (statute of limitation) និងទីពីរ រាប់បញ្ចូល ការវិនិច្ឆ័យសេចក្តីនៅក្នុងរដ្ឋស្នើសុំ ដោយគ្មានវត្តមានរបស់ជនល្មើស។ មូលហេតុមួយចំនួន ទទួលឥទ្ធិពលពីការលើកកម្ពស់ ឬការពារសិទ្ធិមនុស្ស។ ដូចជាករណី បញ្ជូនទៅរងនូវទោសប្រហារជីវិត សន្ធិសញ្ញា ទាមទារឲ្យមានការសុំការធានាកុំឲ្យទោសប្រហារជីវិត ត្រូវបានអនុវត្ត ដោយសារ ស្ថានភាពមុនសម្លាប់ (death row phenomenon) http://www.measboralaws.com/detail/167 ឬ វិធីសម្លាប់ អាចជាអំពើអមនុស្សធម៌ បំពានមាត្រាសិទ្ធិមនុស្ស http://www.measboralaws.com/detail/1041 ។ អនុសញ្ញា ស្តីពី ការប្រឆាំងនឹងអំពើទារុណកម្ម មាត្រា ៣ ហាមមិនឲ្យធ្វើបត្យាប័ន ប្រសិនបើជននោះនឹងទទួលរងគ្រោះដោយសារអំពើទារុណកម្ម ក្រោយពេលបញ្ជូនទៅ។

**៥.** ក្នុងដំណើរការធ្វើបត្យាប័ន វាក៏ទាមទារនូវការគោរពសិទ្ធិមនុស្ស និងអធិបតេយ្យភាពរបស់រដ្ឋផងដែរ។ ក្នុងន័យនេះ គោលការណ៍ពិសេស (principle of speciality) ត្រូវបានចែងក្នុងសន្ធិសញ្ញាបត្យាប័ន និង ទាមទារ

ឲ្យគោរព។ រដ្ឋទទួលមិនត្រូវចោទប្រកាន់ជនល្មើស ក្រៅពីបទល្មើស មានចែងក្នុងសំណើបត្យាប័ន ហើយបើចង់ធ្វើ ត្រូវសុំការអនុញ្ញាតពីរដ្ឋបញ្ជូន។

**កំណត់សំគាល់**៖ កម្ពុជាមានសន្ធិសញ្ញាបត្យាប័នជាមួយរដ្ឋមួយចំនួន ដូចជា ចិន ឡាវ កូរ៉េខាងត្បូង វៀតណាម។ បន្ថែមពីលើនេះ កម្ពុជា បានចុះកិច្ចព្រមព្រៀងស្តីពីការផ្ទេរទណ្ឌិត http://www.measboralaws.com/detail/853 និង ជួយគ្នាទៅវិញទៅមកក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ដូចជា ការជួយប្រមូលភស្តុតាងជាដើម http://www.measboralaws.com/detail/854 ។ កម្ពុជា និងសហរដ្ឋអាមេរិក បានចុះកិច្ចព្រៀងមិនបញ្ជូន ជនសង្ស័យទៅតុលាការព្រហ្មទណ្ឌអន្តរជាតិ http://www.measboralaws.com/detail/848 ។ សម្រាប់ច្បាប់ក្នុងស្រុក ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ បានចែងលម្អិតក្នុង គន្ថីទី៩ (នីតិវិធីដោយឡែក) ជំពូកទី២ អំពីបត្យាប័ន http://www.measboralaws.com/detail/275 ។ ក្រៅពីនេះ ច្បាប់ដោយឡែក ដូចជា ច្បាប់ស្តីពី ការត្រួតពិនិត្យគ្រឿងញៀន មាត្រា ១១២ ចែងអំពីបត្យាប័តផងដែរ ទោះបីមិនលម្អិតក្តី។

**ឯកសារយោង**៖ ១. Geoff Gilbert, *Extradition* in Dinah L. Shelton, Encyclopedia of Genocide and Crime against Humanity, v. 1, 2005, pp.334-341។ ២. Annalisa Ciampi, *Extradition* in Antonio Cassese, the Oxford Companion to the International Criminal Justice, 2009, pp. 321-322។ ៣. Joshua Dressler, Encyclopedia of Crime and Justice, 2002, p. 1698.